គំនិតរបស់ខ្ញុំទាំងមូលក្នុងពេលនេះ ត្រូវបង្វែរទៅរកនឹកភ្នកដល់បុរសជាសាស្ត្រាចារ្យនៅឯបន្ទប់ងងឹតមួយនោះ។ លោក Will ដ៏សង្ហាម្នាក់នោះ!

គិតដល់គេហើយ ខ្ញុំក៏ដកដង្ហើមធំ។

ដោយដកទូរសព្ទដៃរបស់ខ្ញុំចេញមក ចិត្តខ្ញុំសម្រេចចិត្តភ្លាមៗថា យកល្អធ្វើជាប៉ូលិសម្នាក់គួរបញ្ជាប់ទំនាក់ទំនងជាមួយគាត់ មុនពេលបាត់បង់មួកនិងសក្តិការងារពីលើស្មារបស់ខ្ញុំ។

ដូច្នេះខ្ញុំផ្តើមទូរសព្ទទៅកាន់ការិយាល័យរបស់គាត់ សំឡេងស្វ័យប្រវត្តិតបឆ្លើយៈ

«នេះគឺជា William Cadotte! ខ្ញុំមិននៅទេឥឡូវនេះ បើទុកសារ ខ្ញុំនឹងទូរសព្ទទៅវិញ។ ម៉ោងធ្វើការរបស់ខ្ញុំគឺពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពីម៉ោងមួយទៅដល់បីរសៀល»។

ខ្ញុំក្រឡេកមើលនាឡិការបស់ខ្ញុំ.....មានអារម្មណ៍ថា នឹកស្នាមញញឹមស្ដែងៗ ក្បែរៗមាត់គ្នា....នឹកមែន។

ប៊ីប!

ងាកមកប៉ះលោកនាយតាមឃ្លាំខ្ញុំ។

«Jessie» លោកនាយ Clyde និយាយឡើង។

ខ្ញុំបានដកដង្ហើមធំឆ្លើយ«ចាស៎»

«ខ្ញុំនឹងទៅពិនិត្យមើលកន្លែងរបស់ Karen Larson! តែ....ជេស៊ីឯងមិនចាំបាច់ទៅទេ!»

ខ្ញុំងក់ក្បាលយ៉ាងញាប់។ បានគេចពីគាត់បន្តិច ក៏ធូរទ្រូងដែរ។ បន្តមក ខ្ញុំត្រូវបានធ្វើដំណើរតាមផ្លូវហាយវេ វិថី199 ក្នុងឡានល្បាតរបស់ខ្ញុំដដែលជាមួយអ្នកប្រមាញ់ចចក លោក Mandenauer។ បុរសកំពូលអួតម្នាក់នេះ ស្ងាត់ស្ងៀមណាស់មួយចប់តាមផ្លូវ តែពេលណាឡានខ្ញុំអែបដល់កន្លែងកើតហេតុទើបខ្ញុំសម្គាល់ឃើញថា តាមពិតគាត់ស្ងៀមព្រោះលបផ្ទៀងទៅខាងក្រោយសំងំគេង។

បានបន្តិចឃើញគាត់ភ្ញាក់។

«ជួយប្រាប់ខ្ញុំអំពីឧបទ្ទវហេតុទាំងអស់! រឿងណាក្តីដែលខ្ញុំគួរដឹងនោះ ឱ្យខ្ញុំបានបញ្ចប់រឿងនេះ លឿនតាមដែលអាចធ្វើបាន!»

គាត់សម្លឹងមកខ្ញុំផងនិយាយផង ដោយចេតនាបង្ខំខ្ញុំតាមឆន្ទៈរបស់គាត់តែម្ខាង។

«លោកបានអានរបាយការណ៍របស់ខ្ញុំខ្លះហើយមែនទេ?»

គាត់ងក់ក្បាល។ ឆ្លៀតពេលកំពុងតែមានសន្តិភាពនេះ ខ្ញុំគិតដល់ស្លាកអលង្ការដែលរើសបាន និងអាកប្បកិរិយាឆ្កួត ទាន់ហន់យ៉ាងចម្លែករបស់គ្រូបង្វឹកវ័យជំទង់នាងឡាសុន ខារ៉ែន។ ខ្ញុំមិនគិតថា Mandenauer អាចស្វែងរកចចកបាននោះទេ ទោះបីជាខ្ញុំប្រាប់គាត់អំពីរឿងស្លាកដែលខ្ញុំរើសនោះក្តី។ ប៉ុន្តែ ខ្ញុំត្រូវបានគេឆ្កឹះចិត្តឡើងឆ្អែតរួចទៅហើយនៅក្នុងថ្ងៃនេះ ដោយសារតែមិនបានសរសេរលម្អិតគ្រប់យ៉ាងណាតាមដែលខ្ញុំដឹងនិងរាយការណ៍ទៅមេ។ រហូតមកដល់ពេលនេះខ្ញុំនៅតែបន្តពិចារណានូវអ្វីដែលខ្ញុំគួរប្រាប់ និងអ្វីដែលខ្ញុំមិនគួរប្រាប់ទៅអ្នកចាប់ចចក Mandenauer។

«ត្រូវមេខឹងហ្មែន?»

មនុស្សនេះស្រាប់តែសួរមកខ្លី ខ្ញុំក៏ក្រឡេកមើលគាត់វិញយ៉ាងលឿន។ ទឹកមុខខ្ញុំប្រហែលជាហេតុផលគាត់សួរ ព្រោះថាគេនេះមិនសមដឹងអ្វីលើសពីហ្នឹងទេ កាលមេខ្ញុំស្តីឱ្យ ទ្វារចូលការិយាល័យត្រូវបានបិទ ណាមួយលោកClyde របស់ខ្ញុំ មិននិយាយរឿងកូនចៅឯងប្រាប់មនុស្សនេះដាច់ខាត ខ្ញុំជឿ។

ព្រោះខ្ញុំមិនមាត់រក Mandenauer ហើយបានចេញពីឡាន គេនេះក៏ចេញមកតាមក្រោយដែរ។

«ធ្វើចិត្តឱ្យទូលាយបន្តិច ល្អ!»

គាត់និយាយមកពីក្រោយខ្ញុំ ឯខ្ញុំធ្វើជាមិនឮនោះទេ។ ខ្ញុំបានយល់ព្រមនាំគាត់មកដល់ទីនេះ ក្នុងនាមជាប៉ូលិសស្រីម្នាក់ធ្វើការល្អហើយ គាត់មិនបាច់បង្រៀន ទូន្មានខ្ញុំច្រើនលើសទេ។

«ឥឡូវនេះ ប្រសិនបើអ្នកនាំខ្ញុំឆ្លងកាត់កន្លែងកើតហេតុ និងបង្ហាញខ្ញុំពីកន្លែងដែលចចកបានរត់ទៅ និងកន្លែងដែលវាបាត់ខ្លួនចុងក្រោយ ខ្ញុំនឹងដឹងគុណបំផុត»។ បុរសនេះនិយាយបន្ថែម។

ខ្ញុំបានចង្អុលទៅសញ្ញារអិលពីរថយន្ត SUV របស់កញ្ញា Larson។

«ចម្ងាយនេះបង្ហាញថា នាងមិនបើកលឿនទេ ប៉ុន្តែនាងមិនបានចុចសញ្ញាស៊ីផ្លេព្រមាន!»

និយាយបានប៉ុណ្ណឹងខ្ញុំបានចង្អុលទៅផ្លូវលំជាយព្រៃ។

«ផ្លូវនេះមានសល់ដានឈាម ដែលខ្ញុំបានចូលទៅ គឺតាមផ្លូវនេះ»

ថាចប់ខ្ញុំដើរទៅមុន។ អ្នកចាប់ចចក ក៏បានដើរតាមខ្ញុំ។ ទេ ខណៈយើងកំពុងពិនិត្យភស្តុតាងក៏ដូចជា គ្មានឃើញអ្វីថ្មីសោះ។

ចរាចរណ៍មមាញឹកកំពូលសម្រាប់ផ្លូវហាយវេ 199 គឺយប់ថ្ងៃសុក្រនិងរសៀលថ្ងៃអាទិត្យ។ ដូច្នេះទីនេះតែក្លាយជាផ្លូវវាង។ ខ្ញុំឈានចុះសសៀរតាមមាត់ច្រាំងទន្លេ ហើយបោះជំហានជាន់ពីពន្លឺថ្ងៃភ្លឺចិញ្ចាច ចូលទៅជ្រកក្រោមម្លប់ឈើដ៏សាខាមួយសិន។

មានកន្លែងខ្លះក្នុងព្រៃនេះ ជ្រៅបន្តិចទៀតគឺព្រៃស្រោងខ្លាំងណាស់ ព្រះអាទិត្យមិនដែលជ្រៀតចូលដល់ទេ គ្រប់យ៉ាងងងឹតកាន់ខែឆ្នាំ ហើយខ្ញុំ....មិនចូលចិត្តកន្លែងទាំងនោះទាល់តែសោះ ប្រសិនអាចជៀសវាងបាន។

ប៉ុន្តែ....គេនៅទីនោះ....ប្រុសអាក្រាតម្នាក់ដែលឆាបយកការគិតស្រមៃរបស់ខ្ញុំច្រើនថ្ងៃហើយ។

ខ្ញុំបានដើរក្នុងទិសដៅដដែល ទោះជាដានផ្លូវឈាមត្រូវបានបាត់រូបរាងហើយក្តី។ អ្វីៗគ្របដណ្តប់ដោយភាពកខ្វក់នៃសំណល់ស្លឹកឈើក្រៀមដែលត្រូវភ្លៀងធ្លាក់ខ្ទេចរ៉ល់។

យប់នោះក៏ដោយ ប្រសិនគ្មានពន្លឺភ្លឺថែងចាំងនៃព្រះចន្ទដ៏ធំចម្លែក ខ្ញុំក៏នឹងពិបាកចូលដល់ជាមួយពិលមួយដែរ។

«ជេស៊ី? ប្រាកដថាផ្លូវនេះ?» បុរស Mandenauer កំពុងតែបន្តដំណើរតាមមកហើយសួរ។

«ជឿខ្ញុំទេ?» ខ្ញុំសួរខ្លី។

ប៉ុន្តែចិត្តខ្ញុំលបគិតយ៉ាងវែងឆ្ងាយ។ សាស្ត្រាចារ្យម្ចាស់បេះដូងខ្ញុំម្នាក់នោះ ត្រូវទៅក្នុងព្រៃជ្រៅរបស់គាត់យ៉ាងម៉េច? គឺ មិនអាចបើកបរចូលបានទេ ព្រោះអត់មានផ្លូវ។ គេចាំបាច់ត្រូវចតឡាននៅកន្លែងណាមួយ ហើយដើរចូលពិតណាស់។

ដង្ហើមរបស់ Mandenauer តឹង ខណៈគាត់បានឈប់ជើង។ ខ្ទមមួយ លេចចេញមកដូចអ្វីដែលយើងធ្លាប់តែឮគេតំណាលចេញពីរឿងនិទានពពួក Grimms' Fairy Tales ។

ព្រៃជុំវិញនេះមានភាពស្រៀវស្រើបនិងងងឹត ត្រូវជាក់ស្រិបសមនឹងសាច់រឿងដែលបង្ហាញពីក្រុមស្តេចចចក និងមេធ្មប់ដែលស៊ីសាច់មនុស្សឆៅ។

Mandenauer ឱនមើលដីរួចរើសយកភាពកខ្វក់ មួយបាតដៃលើកយកមកហិត។

«ម្ចាស់ផ្ទះនេះ មានបញ្ហាហើយ!» លោកMandenauer និយាយហើយសម្លឹងខ្ទមនោះ។  ខ្ញុំឡើងកាំជណ្តើរ តម្រង់ទៅរកមាត់ទ្វារ។ គ្មានអ្នកណានៅផ្ទះទេ ខ្ញុំគិតបែបនេះមកពីអត់ឃើញមានឡានមាត់ព្រៃ។ ខ្ញុំគោះទ្វារ....គ្មាននរណាឆ្លើយទេ។

យឺតៗ ខ្ញុំឈានលបៗ ទៅក្បែរបង្អួចនិងបិទភ្នែកម្ខាងពិនិត្យទៅក្នុងផ្ទះ។

«ចម្លែតយក្ស!» ខ្ញុំស្រែកមិនដឹងខ្លួនព្រោះភ្ញាក់ពេលឃើញ ចចកមួយនៅក្នុងនោះកំពុងតែមើលមកខ្ញុំវិញ។

ខ្ញុំលោតថយក្រោយជើងពីរជើងបី បេះដូងក៏លោតញាប់ ខ្យល់ដង្ហើមចេញចូលយ៉ាងវែងបង្ហួស។ បាតដៃខ្ញុំទះគូទរាវរកកាំភ្លើងនិងដកយកមកក្ដាប់.....ណែនមែនទែន!

គ្រប់វិនាទីនេះ ខ្ញុំគិតថា សត្វកំណាចនឹងបំបុកកញ្ចក់ ហើយលោតមកត្របាក់យកឈាមពីបំពង់ករបស់ខ្ញុំ។ ....គ្មានអ្វីកើតឡើងទេ។

ខ្ញុំងាកផ្ដោតទៅបង្អួចនោះ សឹងថាមិនហ៊ានព្រិចភ្នែកសោះ ហើយក៏ស្រាប់នឹកឃើញដល់ភ្នែកក្រហមនៃអ្នកគ្រូក្មេងឡាសុនខារ៉ែនពេលនាងពុល។ មុនពេលនាងស្លាប់ គឺនាងរញ៉េរញ៉ៃ នៅពីក្រោយភាពឆ្កួតលេលាដែលគ្របសង្កត់នាងបណ្ដាលមកពីមេរោគ ហើយខ្ញុំអណោចអធម៌ថា នារីនោះនាងពិតជាភ័យខ្លាចខ្លាំងណាស់ដែលខ្លួនឯងធុំក្លិនហើយចង់តែខាំត្របាក់អ្នកដទៃ។

ខ្ញុំបានរេខ្លួនប្ដូរទៅសំងំលបមើលលើគែមនៃរានហាលមុខខ្ទមធ្មប់ តែមិនទាន់បានធ្វើសកម្មភាពអ្វីផង។ សំឡេងចចកលូលាន់ឮមកពីចម្ងាយ។ ខ្ញុំរេភ្នែករកប្រភពសំឡេងលូទាំងចិត្តពិភាល់ណាស់។ តែដោយសារវានៅឆ្ងាយពេកមិនអាចចាប់ប្រភពបានទេ តែសំឡេងនោះបានធ្វើឱ្យខ្ញុំលោតចុះពីលើគែមក្បែរបង្អួច ហើយប្រញាប់ថយមករកកន្លែងដែលបុរសចាប់ចចកកំពុងនៅ។

យ៉ាប់ហើយ! ជននេះមិននៅទេ។ ខ្ញុំម្ហូម៉ៅណាស់ ដេរដាក់បណ្ដាសានៅពេលដែលខ្ញុំរត់តាមរកគាត់ ដើរតាមគន្លងចាស់ៗរបស់យើងពេលឈានមក  ខ្ញុំបន្ទោសខ្លួនឯងថា គួរព្រមានគាត់កុំឱ្យវង្វេង ឬដើរបែកគ្នា បើគាត់មានរឿងអី លោកនាយខ្ញុំច្បាស់ជា......ហ៊ឹម។ ចំនួនអ្នកបាត់បង់ជីវិតក្នុងព្រៃនេះមានតួលេខមកជារៀងរាល់ឆ្នាំ ហើយតែងកើនចំនួនច្រើនឡើងៗគួរឱ្យកត់សម្គាល់។ លោតែឥឡូវនេះ ខ្ញុំចេញទៅវិញម្នាក់ឯងដោយបាត់បង់អ្នកប្រមាញ់ចចក ជាវរជនកំពូលអួតរបស់លោកនាយ Clyde ឈ្មោះរបស់ខ្ញុំនឹងត្រូវគេស្ដីបន្ទោស ឬជាប់សង្ស័យអស់មួយជីវិត។

«ឮ! ឮ! ឮខ្ញុំទេ?»

ខ្ញុំស្រែកហើយមិនឮអ្វីមកវិញសោះ។ បុរសចំណាស់អ្នកចាប់ចចកដែលនៅសុខៗបាត់ខ្លួនកាន់តែបង្កើនការភ័យភិតទ្វេក្នុងអារម្មណ៍ខ្ញុំលើសពីវត្តមានចចកពិតទៅទៀត។

ខ្ញុំបានដើរផងរត់ផងជុំវិញនោះហើយរកឃើញថា សូម្បីសម្រិបឬសំឡេងសត្វស្លាបក៏ស្ងាត់បាត់ដែរ។ មានអ្វីមួយកំពុងត្រៀមនឹងកើតឡើង.....សំឡេងចចកលូលាន់យ៉ាងវែងអន្លាយមកម្ដងទៀត តែលើកនេះ កាន់តែខិតជិតកន្លែងខ្ញុំ។

....ហើយចចកទីពីរបានឆ្លើយឆ្លងដោយលូរកគ្នាវិញ! ខ្ញុំឈប់ជើង វេខ្លួនរង្វង់ ហើយក្ដាប់កាំភ្លើង ធ្វើភ្នែកមុតខំសមាធិអារម្មណ៍ឱ្យបានមូល។ តែសំណួរនៅតែលេចមក។

ហេតុអ្វីបានជាចចកមកលូខុសប្រក្រតីនៅពេលថ្ងៃទៅវិញ? លោក Mandenauer បានជំពើបនឹងសត្វអស់នោះ? គាត់មិនមានកាំភ្លើងទេ!

ហ៊ឺម!

សំឡេងស្រិបៗជាន់លើ បញ្ចេញមកពីប្រភពចំហៀងខ្ញុំ។ ខ្ញុំក្រឡេកមើលភ្លាម វាពិតជាមានរំញ័រ....ខ្ញុំរារែក....ធម្មតានៅក្នុងព្រៃងងឹតហើយស្ងាត់ការចាប់ប្រភពឬទិសនៃ សំឡេងអាចច្រឡំដោយសារការខ្ទរមកវិញ។ បើមានវាល ក្នុងពន្លឺថ្ងៃវាងាយនឹងរកជាងនេះ។

«លោកMandenauer?» ខ្ញុំបានស្រែកសួរហើយបង្អាប់ឡើង

«បើពូមែន ត្រលប់មកណេះវិញភ្លាម!»

គ្មានចម្លើយ។ ដង្ហើមរបស់ខ្ញុំញ័រព្រោះខ្ញុំឃើញគុម្ពោតពិតជារង្គើ បេះដូងរបស់ខ្ញុំបានចេញចង្វាក់ផ្គរលាន់ ញើសហូរនៅចន្លោះដើមទ្រូងខ្ញុំ ហើយស្រក់ចុះមកលើពោះខ្ញុំ។ ខ្ញុំចាប់ផ្ដើមស្រែកម្ដងទៀត៖

«បាញ់ហើយណ៎ា»

ចលនាមួយបង្ហាញឡើងនៅជ្រុងនៃចក្ខុវិស័យរបស់ខ្ញុំ បានធ្វើឱ្យខ្ញុំគ្រវីក្បាល ហើយចង្អុលអាវុធរបស់ខ្ញុំក្នុងទិសដៅនោះ។

«នាងធ្វើឱ្យវារត់រួចហើយ!»

តាមពិតបុរសនេះសំងំចាំចាប់ចចក? គាត់បានគ្រវីក្បាលបន្ទោសខ្ញុំរួចគាត់ចេញពីគុម្ពោតមួយនោះមកមែន។ សត្វនោះបោលក្អួងចេញយ៉ាងរហ័សពេកណាស់នឹងរកអ្វីមកប្រៀបធៀបបាន។

«ចចក?» ខ្ញុំបានសួរចំហមាត់។

គាត់ងក់ក្បាល។

«តែមិនអីទេ! វាមិនមែនសត្វឃាតកៈដែលខ្ញុំស្វែងរកទេ»

ខ្ញុំបានក្រឡេកមើលថាគាត់និយាយលេងឬមែន៖

«ម៉េចពូដឹង?»

«ខ្ញុំដឹង! វាតូចៗគ្មានកម្លាំងខាំគ្រូក្មេងនាងឡាសុនខារ៉ែនទេ!»

ស្អីក៏ដោយពេលនេះខ្ញុំធុញណាស់ ខ្ញុំចង់ចេញពីទីនេះ។

«រួចរាល់?» ខ្ញុំបានសួរ។ ពេលគាត់ដើរមក ខ្ញុំឃើញកាំភ្លើងគាត់លៀនចេញ។ គាត់មិនមែនដៃទទេទេ។ ហ៊ឹមខ្ញុំទេយ៉ាប់។ ខ្ជិលប្រាប់ថាខ្មមនោះមានចចកមួយ ខ្ញុំចង់ទៅផ្ទះ។

«ថ្ងៃនេះប៉ុណ្ណឹងក៏បាន! ក្រោយទៀតខ្ញុំមិនរំខាននាងទេ!»

ខ្ញុំក្រឡេកមើលទៅដោយភ្ញាក់ផ្អើលទៅគាត់ដោយអន់ចិត្តប្រហែលគាត់គិតថាខ្ញុំវ៉ៀរវ៉ៀ?

## រាត្រីស្នេហ៍

ខ្ញុំរំកិលទាញឡាន Crown Victoria របស់ខ្ញុំចូលទៅទុកក្នុងចំណតព្រោះវាក៏ដូចខ្ញុំ យើងត្រូវការសម្រាក ហត់ហើយ។

ចេញមក ខ្ញុំសម្លឹងមើលផ្ទះតូចឯកោក្នុងរដូវក្ដៅនេះ។ វាក៏ឯកាដូចខ្ញុំដែរ។ នេះជាដីដែលខ្ញុំទិញបាន ព្រោះស្រឡាញ់ទីក្រុងស្ងាត់ដោយព្រៃមួយនេះ វាប្រហនឹងមាត់បឹង ឆ្ងាយបន្តិចតែខ្ញុំជាប៉ូលិសម្នាក់....អូខេ។

ផ្ទះខ្ញុំកប់បាត់ក្នុងផ្នែកងងឹតនៃស្រមោលព្រៃក្បែរៗ ដែលពិតជាបានកាត់បន្ថយការទាក់ទាញពិតរបស់វាបើពេលថ្ងៃវិញ អ្នកដឹងហើយថា ហេតុអ្វីខ្ញុំស្រឡាញ់ទីនេះខ្លាំង។

ងូតទឹកលើកនេះលឿនណាស់ ព្រោះមិនចង់គេងលក់នៅក្នុងនោះទៀតទេពោះខ្ញុំអត់មានអ្វីញ៉ាំច្រើនម៉ោងហើយ។

ដោយមានអីទ្រាប់ពោះបន្តិច ក៏កាន់កែវសូដាមកអង្គុយនៅលើគ្រឿងសង្ហារឹមក្នុងរានហាលជាន់ទីមួយ ដែលខ្ញុំកម្រប្រើព្រោះគ្មានពេលមើលទិដ្ឋភាព។

ថ្ងៃនេះហត់ តែមិនចង់គេង ចង់មើលដើមឈើថាវាបានបានដាក់ស្រមោលលើទីធ្លាខ្ញុំដោយមិនសុំការអនុញ្ញាតយ៉ាងម៉េចខ្លះ?

ទូរសព្ទរបស់ខ្ញុំនៅតែក្បែរៗខ្លួន ថ្មីៗនេះខ្ញុំដូចជាស្មារដែរចាំទូរសព្ទអ្នកណាម្នាក់មិនដឹង។ ទូរសព្ទជាប់នឹងអ្នកកាន់។ ហេតុអ្វីសាស្ត្រាចារ្យនោះឮ Voice mail ពីខ្ញុំហើយ មិនទូរសព្ទមក? ខ្ញុំត្រូវការយក

ស្លាកមួយនោះមកវិញមុនពេលលោកនាយ Clyde ដោះមួកខ្ញុំយកឡានទៅវិញខានជិះ ហើយខ្ញុំអស់ការងារធ្វើ ក្នុងឈ្មោះជា Officer។

ដៃខ្ញុំឱបក្នុងអាវរំភើយពណ៌គគីរ ជាសូត្រស្តើងខ្ញុំកម្រនឹងពាក់ព្រោះគ្មានបុរសណានឹងឃើញវាទេ។ វាជាអាវរាត្រីដ៏ស្អាតមួយស្រីគ្រប់គ្នាចង់ថ្នមខ្លួនជាមួយវា នៅពេលយប់ៗទ្បើង។

អស់សូដា!

ខ្ញុំបែរចូលក្នុងហើយចាក់បន្ថែម។ ពេលចូលទៅខាងក្នុង ខ្ញុំបានមើលទៅកាំភ្លើងរបស់ខ្ញុំ ដែលដាក់នៅលើទូទឹកកក ហើយទុកគ្រាប់កាំភ្លើងនៅក្នុងហោប៉ៅអាវក្រៅដែលខ្ញុំព្យួរក្បែរនោះ។ ធម្មតាទេ ការប្រុងប្រយ័ត្នជារឿងអាទិភាពសម្រាប់ស្ត្រីម្នាក់ដែលរស់នៅម្នាក់ឯងបែបខ្ញុំ។

វិធីនេះ បើនរណាម្នាក់ឃើញកាំភ្លើងនោះ ហើយយកវាមកប្រើគេនឹងគ្មានគ្រាប់ទេ។ បើខ្ញុំត្រូវការវាខ្ញុំដឹងថា គ្រាប់កាំភ្លើងនៅឯណា។

មានអ្វីមួយបង្ហាញខ្លួននៅកន្ទុយភ្នែក។ ខ្ញុំក្រឡេកមើលទៅទិសដៅនោះ តែក៏គ្មានអ្វីក្រៅពីយប់ខ្មៅមួយ ផ្លាតមកពេញកញ្ចក់បង្ហាញរូបរាងខ្ញុំខ្លួនឯងផ្ទាល់។

ខ្ញុំដើរឆ្លងកាត់កន្លែងរស់នៅតូចច្រលឹងនេះ ចាប់សោរទាញបិទរនុក ទ្វារបញ្ចប់សព្វសំឡេងចង្រិតស្រែកនិងសន្ធឹកខ្យល់ឈ្លោះដើមឈើ។ ខ្យល់ត្រជាក់បក់បោកមួយរំឹងចុងក្រោយចូលក្នុងបន្ទប់។ ខ្ញុំមិនដែលដឹងរហូតដល់យប់នេះថា ផ្នែកខាងក្រៅនៃអគារនេះងងឹតថ្នាក់នេះទេ។

ទ្បើងមកអង្គុយនៅលើយ៉ាន់ទីមួយវិញដដែល ទាំងគ្មានប្រដាប់អាវុធទេ។ សន្មត់ថា សម្រាកចិត្តទៅជេស៊ី។ ខ្ញុំប្រាប់ខ្លួនឯងខណៈបេះដូងហាក់ត្រូវការអ្វីមួយអាចំកំបាំង។

តើអ្វីនាំខ្ញុំទ្បើងមកលើនេះអង្គុយ? អូខេ អាចថា សូម្បីតែចចកគ្រោសធំមកដល់ក៏នឹងមិនអាចលោតទ្បើងកម្ពស់ ហាសិបហ្វីតមករកខ្ញុំដែរហ្ន៎។

ដោយសារខ្ញុំស្អប់ការគិតអំពីចចកដដែលៗ ខ្ញុំបានឈានទៅបង្កាន់ដៃរានហាល ផ្អៀងកំភួនដៃក្រៅដែកនេះ ដោយមានកំប៉ុងដាក់សូដាក្នុងបាតដៃ។ មានអ្វីមួយធ្លាក់ប៉ឹងមកនៅតាមគែមនៃស្រមោលព្រៃ។ ខ្ញុំជ្រួញចិញ្ចើម! វានោះទាបបាត់ដល់ដីតែមួយរំឹងនោះខ្ញុំឃើញថា វាទៅបាត់ជាមួយកន្ទុយ។

«ហេយ៉ូ!» ខ្ញុំភ្លាត់មាត់ភ្ញាក់ផ្អើល។

ខ្ញុំខំផ្តោតមើលមុតៗដូចស្តេនតាមបណ្តាបន្ទាត់នៃដើមឈើម្តងមួយៗ ទាំងដង្ហើមខ្ញុំអត់ផ្ចត់សឹង មិនហ៊ានដកទៀត។ ប៉ុន្តែយប់ងងឹតពេកអត់ព្រះចន្ទផង។

ងាកមកសម្លឹងមើលទៅលើមេឃ វិញខ្ញុំចាប់បានពន្លឺព្រះចន្ទពណ៌ប្រាក់ ដែលព្យុះបានត្រឹមពាក់កណ្តាលខ្មៅ។

ការទង្គិចជើងទល់នឹងថ្មរានហាល ទាញចំណាប់អារម្មណ៍របស់ខ្ញុំឱ្យទម្លាក់ភ្នែកពីលើមេឃមកដី។ បុរសម្នាក់ប្រាកដកាយ ឈរនៅក្រោមសំយ៉ាបផ្ទះរបស់ខ្ញុំ។ កំប៉ុងសូដាបានរអិលចេញពីដៃរបស់ខ្ញុំ ដោយភាពរន្ធត់មួយរឹបតែជននោះលូកដៃវែងនិងធំ មកឆក់យកកំប៉ុងពីអាកាសមួយវិនាទីបានមុននឹងវាធ្លាក់ដល់ដី។ សូដាស្រោចពេញពីលើគេ។

ភ្នែកខ្ញុំនឹងគេប្រសព្វគ្នាជាការសម្លឹងដែលបេះដូងខ្ញុំ.....លោតសណ្តុំក្តៅៗ។

«ទម្លាប់បោះដាក់អ្នករាល់គ្នាតែអ៊ីចឹង ឬក៏ស៊ីញ៉ូខ្ញុំ?»

«Will?»

ខ្ញុំហៅឈ្មោះគេដែលទន្ទេញនឹកពេញបេះដូង។

«មិនគួរចេញមកក្រៅពេលយប់អ៊ីចឹងទេ អាចជួបព្រានសុិច»

គេនេះនិយាយកំប្លែង តែថ្មើរណេះម៉ោងណេះខ្ញុំ មិនគិតថាខ្ញុំចាប់អារម្មណ៍នឹងពាក្យកំប្លែងទេ។ គេនេះលើកកំប៉ុងសូដាបាចបង្ហូរទឹកដែលនៅសល់ទៅលើអាកាសហើយក្រេបត្រេងយកមកយ៉ាងវែង និងយ៉ាងថ្នឹក។

ខ្ញុំបានឃើញថា ខ្លួនឯងចាប់អារម្មណ៍ខ្លាំងពេកហើយ ជាមួយនឹងសាច់ដុំដែលអាចបត់បែនបាន និងបញ្ចេញគំនួចលើបំពង់កដ៏ធំរបស់គេ។

វិធីដែលគេឆក់យកតំណក់ទឹកចេញពីកម្លាំងខ្យល់ពិតជាអស្ចារ្យណាស់។

«ប៊ិនម៉េះ? ធ្វើដោយរបៀបណា?» ខ្ញុំបានសួរពីលើទៅ។

គេបង្អួតខ្ញុំបន្ថែមដោយញីកម្ទេចសម្បកកំប៉ុងនៅក្នុងដៃ។ បេះដូងខ្ញុំលោតញាប់ឡើងចាញ់ភាពទាក់ទាញ។

ខ្ញុំក្រពាត់ដៃឱននិយាយរីករាយ៖

«ដូចជាកំពុងអួតថាខ្លួនឯងជាមនុស្សអស្ចារ្យ»

«នៅមានរឿងអស្ចារ្យច្រើនទៀត!» គេងើយមកទាំងញញឹម «ចង់ឃើញ?»

បុរសម្នាក់នេះមានអានុភាពមកចែចង់បានខ្ញុំយ៉ាងស្រួលដូចដកដង្ហើម។ ប៉ុន្តែហេតុអ្វីបានជាគេចូលចិត្តចែចង់ខ្ញុំនេះទើបជាសំណួរសំខាន់?

«អត់ចង់ទេ! អរគុណ!» ខ្ញុំតបខែងរ៉ែងណាស់

«ហើយមកធ្វើអ្វីនៅណេះ?»

«ឃើញសាររបស់ជេស៊ីខ្ញុំមកភ្លាម!»

គេបានលូកដៃចូលទៅក្នុងហោប៉ៅខោខូវប៊យហើយកាន់អ្វីមួយនៅចន្លោះមេដៃនិងចង្អុលដៃ។ ព្រះចន្ទបានចេញមកភ្លឺចិញ្ចាចទោះត្រឹមមួយចំណិត។ ពេលនេះខ្ញុំអាចមើលឃើញមុខសង្ហានិងមានស្នេហ៍របស់គេ ចំណែកឯរបស់នៅចន្លោះរវាងម្រាមដៃរបស់គេគឺស្លាកមាសរបស់ដែលមេខ្ញុំបញ្ជាឱ្យរក។

«ឡើងមក! មានកាហ្វេញ៉ាំ!» ខ្ញុំអញ្ជើញគេ

«មានសល់មួយពែង យើងចែកគ្នា!»

«ចែកគ្នា?» គេសួរបកស្រទន់ហើយងក់ក្បាលក្រឡេកមើលជុំវិញខ្លួន។

ខ្ញុំចូលទៅក្នុងផ្ទះល្វែងវិញទាំងលបញញឹមសប្បាយចិត្ត ប៉ុន្តែខ្ញុំត្រូវបង្ខំចិត្តឈប់មុនពេលគេឡើងមកឃើញ។ ស្នេហានេះទៅមិនរួចទេ គាត់មានចំណេះ ការងារល្អ សង្ហា ស៊ិចស៊ី ឆ្លាតវៃ។ ខ្ញុំជាមនុស្សមធ្យម ទន់ខ្សោយ និង...ហ៊ុមគេស្ទើរតែជាPHD ....សាស្ត្រាចារ្យនិងប៉ូលីស។ វាស្តាប់ទៅ ដូចជាប្រលោមលោកមនោសញ្ចេតនាដែលមានតែសោកនាដកម្មនៅចុងបញ្ចប់។ ក្រៅពីនេះ ខ្ញុំមិនទាន់បានគិតទៅដល់អម្បូរពូជដែល......មិនរំខានខ្ញុំទេ....ប៉ុន្តែអាចរំខានគេ ឬយ៉ាងហោចណាស់គ្រួសាររបស់គេជាត្រកូលតជំនាន់ Ojibwe សង្ស័យថាឪពុកម្តាយរបស់គាត់មិនចង់ឱ្យស្រឡាញ់មនុស្សស្រីធម្មតាទេ។

«វ៉ាស!»

ខ្ញុំស្រែកដោយអចេតនាព្រោះគេនេះមកនៅក្នុងផ្ទះទាំងមិនទាន់បានបើកសោឱ្យ។

«តើ?» បានត្រឹមមួយម៉ាត់នេះ ខ្ញុំក្រឡេកមើលទៅបង្អួចដែលនៅជិតស្លុង ខ្យល់បក់មិនចូលដល់វាំងននទេព្រោះកញ្ចក់ក្រាស់និងមាំ។

«មានន័យថាម៉េច?»

គេបានផ្អៀងក ឈរនឹងនរសង្ហាហើយ បត់បែនដៃទាំងពីទៅក្រោយចង្កេះ...គេខ្ពស់ ក្រាស់និងមានថាមពល។

«ក្រែងប្រាប់ខ្ញុំឱ្យឡើងទៅ!»

«ធ្លាប់គិតចង់ប្រើទ្វារខ្លះទេ? ប៉ុន្តែ....ចូលមកដោយរបៀបណា?"

គេមិននិយាយ ញញឹម។ នេះឬភាពអស្ចារ្យបន្ត? តោងអគារឡើងបានដូចមនុស្សពីងពាង? ខ្ញុំយល់ថាពិបាកនឹងជឿ ប៉ុន្តែគេពិតជាចូលមកមែន។

ខ្ញុំបែរខ្នងទៅចុចទឹកក្តៅតែលបគិត ភ្នែកខ្ញុំមិនល្អទេបើគេឃើញ ភ័យក្រឡិកក្រឡាប់ណាស់។

សាស្ត្រាចារ្យ Will Cadotte ពេលនេះមកតាមខ្ញុំដល់ផ្ទះ ហើយនៅក្រោយខ្នងខ្ញុំទៀត។ ក្រោយពីកាហ្វេនេះត្រជាក់ មានអ្វីកើតឡើង?

ខ្ញុំហុចពែងដ៏ឈ្ងុយឱ្យគេ ហើយនាំមុខឡើងទៅរានហាលដដែលវិញ។ គេនៅឈរចន្លោះពីរវាងខ្ញុំនិងទ្វារ។ ផ្លូវចេញតែមួយគត់សម្រាប់ខ្ញុំ គឺលោតចុះក្រោមបើគេមានបំណងណាមួយមិនល្អ ហើយខ្ញុំប្រុងរត់គេច។

ទោះបីជាគេមិនបង្អួតតែ សាច់ដុំគេគ្រប់កន្លែងកំពុងនាំខ្ញុំឱ្យស្រមៃ.....តើខ្ញុំអាចនឹងយករឿងនេះទេបើគេបរិច្ចាគរាត្រីមួយលេងៗជាមួយគ្នា.....ក្នុងភាពឯកជននិងឯកោបែបនេះ? ខ្ញុំមិនប្រាកដទេ។ ដង្ហើមរបស់ខ្ញុំតឹងនិងញាប់ ខ្ញុំក្រពាត់ដៃខ្ទប់ច្រមុះ កុំឱ្យមានគេដឹងឮអាថ៌កំបាំងនៃតម្រេកខ្លួនឯង។

ដោយរងានិងគ្មានអាវក្រាស់ ខ្ញុំចង់ទៅក្នុងយក។ ខ្ញុំបានដើរចូលទៅរកទ្វារ កន្លែងគេឈរនៅបាំងបិទ។ ប្រសិនបើគេមានសុជីវធម៌ គាត់នឹងគេចចេញតែនេះ.....គេនៅធ្វើមិនដឹងហើយញញឹម....

«សុំស្លាកនោះមក!»

ខ្ញុំបន្លប់ហើយលាដៃឡើង។ គេសម្លឹងមើលដៃខ្ញុំ ប៉ុន្តែមិនបានធ្វើចលនាឬកពាអ្វីដូចចង់ដាក់វាសងមកវិញសោះ។ ភ្នែកខ្ញុំទម្លាក់មកក្រឡេកមើល ហោប៉ៅរបស់គាត់។ មិនដឹងទុកនៅទីនេះឬអត់ទេស្លាកនេះ គួចពេកក្នុងការស្មានដឹងកន្លែងគេនេះទុកវា។ ហោប៉ៅគេមិនប៉ោងទេ ប៉ុន្តែមានកន្លែងមួយប៉ោង ហើយ....ដ៏គួរឱ្យចាប់អារម្មណ៍ ក្បែរៗនោះ។ ខ្ញុំស្ទក់....ហើយជម្នះងើយមុខមកសម្លឹងទៅគេ។

គេឈប់ញញឹមហើយខាំមាត់ខាងក្រោម។ ភ្នែកគេខូចៗ សម្លឹងមកខ្ញុំចង់ប្រាប់ថា គេដឹងហើយ គេដឹងខ្ញុំ«ចង់» គេក៏បានកត់សម្គាល់អ្វីៗទាំងអស់ដែលភ្នែកខ្ញុំលបលួចមើលលើរាងកាយគេ។

គេសសៀរមក ធ្វើឱ្យខ្ញុំដើរថយក្រោយ ហើយជេរខ្លួនឯងក្នុងចិត្តចំពោះភាព«ហាច់»និងបេះដូងមួយសែនទន់ខ្សោយចំពោះគេម្នាក់គត់ ប៉ុន្តែខ្ញុំមិនអាចជួយបានទេ។ ស្បែករបស់គេបានបញ្ចេញកម្តៅខ្លាំងឆ្លងមកដល់ខ្ញុំ ខ្ញុំអាចធុំក្លិនអ័រម៉ូនក្រអូបប្រហើរនៃបុរសម្នាក់ ដែលគ្មាននៅលើភពផែននេះ។

ក្លិនក្រអូបនៃធម្មជាតិព្រៃដែលខ្ញុំបានកត់សម្គាល់កាលពីយប់មួយនោះ ជាក្លិនដែលដាស់អារម្មណ៍ខ្លាំង។ ខ្នងខ្ញុំបានបុករនាំងដែក។ ខ្ញុំមិនអាចថយបន្តទៀតទេតែក៏អរគុណដែល Will Cadotte ឈប់រុលក៏ប៉ុន្តែនៅតែកៀកពេកណាស់។

«សុំទោស!» គេនិយាយស្រាលដូចខ្យល់។ ប៉ុន្តែយ៉ាងហោចណាស់ប្រាណគេមិនបានប៉ះខ្ញុំទេ។ ខ្ញុំមិនប្រាកដថា ខ្ញុំនឹងធ្វើយ៉ាងណាឡើយ ប្រសិនបើគេដាក់បាតដៃដ៏ធំទាំងពីរនោះមកលើខ្ញុំ។

«ប្រសិនបើជេស៊ីមកយកស្លាកនៅសាលា ខ្ញុំមិនមកទេ! តែ...ខ្ញុំសង្ស័យថា ម៉ាដាមអញ្ជើញខ្ញុំមកលេងដល់ទីនេះ»

«ម៉េចដឹងថា ខ្ញុំរស់នៅកន្លែងហ្នឹង?»

«ពិបាកស្អី!»

គេចោលភ្នែកចិញ្ចាចអំនួតសម្លឹងខ្ញុំ។ ហើយបន្ថែមពេលខ្ញុំក្រឡង់ៗចាញ់សម្រស់សំឡេងគេ

«សម្រាប់មនុស្សស្រីដែលខ្ញុំចូលចិត្ត!»

ពិតគ្រប់គ្រាន់ហើយការញ៉ែនេះ។ ខ្ញុំចង់ទាញខ្លួនឯងចេញបន្តិចសិនតែគេបានលូកដៃទាំងសងខាង មកត្រដុសម្រាមលើចុងសក់របស់ខ្ញុំហើយបន្តខ្សាវៗ៖

«ខ្ញុំចង់ជួបម៉ាដាមប៉ូលិសទៀត»

ជាមួយភាពញាប់ញ័រខ្ញុំសួរ៖

«ជួបធ្វើអី?»

គេបានទម្លាក់ដៃចេញ ធ្វើឱ្យខ្ញុំគិតថាគេនឹងជៀសថយក្រោយអនុញ្ញាតឱ្យខ្ញុំឆ្លងកាត់ទៅរកទ្វារ ហើយខ្ញុំស្រមើស្រមៃថា គេនឹងនិយាយពីរឿងឧក្រិដ្ឋដែលត្រូវការឱ្យខ្ញុំលុប ព្រោះគេហៅខ្ញុំម៉ាដាមពីរ

ដងហើយ ខ្ញុំក៏ហៀបនឹងនិយាយថា «Sorry I can't help» ស្រាប់តែ ដៃដែលបានទម្លាក់ចុះមកនោះ គ្របរឹបមកលើត្រគាកខ្ញុំសងខាង។

ភ្នែកគេត្រជាក់ដូចព្រះចន្ទល្ងឹងល្ងើង។ ខ្ញុំភាំងគ្មានពេលនិយាយអ្វីទេ ពីព្រោះគេឱនមករកមាត់ខ្ញុំ ហើយថើបខ្ញុំ។ ដោយសារមាត់ខ្ញុំបើកបានពាក់កណ្ដាល ត្រៀមខ្លួននិយាយ អណ្ដាតរបស់គេមានឱកាសក៏រអិលចូលបាន។ ដៃគេឱបខ្ញុំមាំ ខ្ញុំរើដៃរតែក្រោយមកខ្ជិលវិញ។

បបូរមាត់គេក្រអូបនិងក្ដៅៗ....ដៃខ្ញុំឱបគេ ចំណែក Will ក៏មិនខ្ជះខ្ជាយពេលវេលាដែរ។ គេបានថយចុះក្រោយចូលទៅរករបស់ល្អភ្លាមៗ។

ខ្ញុំចូលចិត្ត ពេលដែលទីតាំងមរតកមនុស្សស្រីបាននៅក្នុងមាត់គេ។

ភ្លេចថានេះគឺកណ្ដាលវាល ខ្ញុំត្រូវចុងអណ្ដាតរបស់គេវាយដំ ស្ទើរស្រែកអស់សំឡេងបាន។

គេនៅមិនឈប់ទេ ខ្ញុំបានរុញគេ រុញស្មាគេចេញយ៉ាងខ្លាំង តែមុខគេនៅជាប់ម៉ឺង ដៃគេព័ទ្ធខ្ញុំឱ្យមាត់គេនៅសោយរាជ្យចំកណ្ដាលល្អាងរបស់ខ្ញុំ ហើយលេងសើចតាមចិត្តគេ។ ខ្ញុំញ័រត្រគាក ទន់ជើងទម្លាក់ខ្លួនទ្រោមលើកំភួនដៃគេ គេនៅមិនរង្គើទៅណា។

ខ្ញុំជិតចេញហើយ.....យូរហើយមិនដែលមានសភាពនេះកើតឡើងទេ។ ប្រុសទាំងអស់ដែលខ្ញុំឃើញជា Gay ពួកគេគួរឱ្យធុញនិងកំប្លែងចុកពោះ តែ will វិញ ពោះខ្ញុំផតចូលក្នុង ទប់ខ្លួនឯងលែងជាប់នឹងការវាយលុកធ្ងន់ៗឥតមេត្តារបស់គេ។ ខ្ញុំមានអារម្មណ៍ដូចជា ក្មេងស្រីគ្មានសមត្ថភាពរឿងលើគ្រែទេ ត្រូវគេគ្រប់គ្រងបានគ្រប់សព្វ ដឹងតែពីស្រែកថ្ងូរតែមិនខ្លាំងទេនិងអង្វរគេឱ្យឈប់បន្តិច តែគេមិនព្វ។

នៅពេលដែលគេព្វខ្ញុំក្នុងជីវិតមួយលែងជាខ្លួនខ្ញុំ គេធ្វើចលនាដ៏ស្រើបស្រាលដោយលូកដៃម្ខាងមករកទាញទម្លាក់ខ្សែអាវដេកយប់ស្តើងគ្មាន អាវទ្រនាប់របស់ខ្ញុំ។ ប៉ះចុងសុដន់ខ្ញុំភ្លាម រំពេចនោះមាត់របស់គេបានចាកចេញពីចំណុចខាងក្រោមឡើងមករកបន្ទាបក្បាលសុដន់របស់ខ្ញុំ។

«អត់ទេwill»

អណ្ដាតដ៏ឈ្លាសវៃនោះដឹងថា ទេគឺបានន័យថា Yes ។ គេបានរុលចូលមកចំណុចកណ្ដាល ហើយលេបខ្ញុំស្រស់ៗខ្លាំងៗ។

ខ្ញុំងើយមុខសម្លឹងមេឃ។ ដឹងថាអាវរ៉ូបនេះប្រើការចំពេលមែន តែវាត្រូវរបូតបាត់ហើយ។ ពីរនាក់យើងជាន់វាខ្ទេចខ្ទីព្រោះរាងកាយរបស់ខ្ញុំត្រូវបានឆេះក្ដៅសន្ធំ ចិត្តខ្ញុំរញ៉េរញ៉ៃទាំងស្រុងទោះលោកនាយមកដល់ ក៏ខ្ញុំនឹងមិនចំណាយពេលរវល់ដែរ។ ដៃខ្ញុំងើបឡើងស្របតាមខ្លួនរបស់គេ ម្រាមដៃទាំងអស់ធ្វើតាមបេះដូង គឺអង្អែលសក់ទន់រលោងរបស់គេ ស្ទាបក្រវិលគេទាំងសោមនស្ស។ មាត់របស់ will បិទដូចជាប់ការមកលើក្បាលសុដន់របស់ខ្ញុំ រួចខាំចុងសុដន់ ខ្ញុំតិចៗដូចក្ដាញ់វា។

ខ្ញុំអង្វរមិនចេញសំឡេងនិងចំកោងខ្លួនឯងទៅក្រោយ ទុករាងកាយទាំងមូលរបស់ខ្ញុំឱ្យគេត្រកងកាន់។

ការគិតច្បាស់លាស់រសាត់ឆ្ងាយទៅៗ បន្សល់នូវសំឡេងថ្ងូរសោកសៅ នៅពាក់កណ្ដាលនៃការឈានដល់ចំណុចកំពូល ជាសេចក្ដីសុខលើកដំបូងដែលខ្ញុំទទួលបានក្នុងរយៈពេលរងាជាច្រើនឆ្នាំ។

វត្ថុធំវែងរបស់គេលូនចូលមកក្នុងខ្លួនខ្ញុំ....វាធំណាស់ ធ្វើឱ្យមានសំឡេងភាន់ច្រឡំសម្រាប់ខ្ញុំថាចចកឬមនុស្ស?

Will Cadotte ងើបក្បាលមកវិញ សម្លឹងមើលស្មារបស់ខ្ញុំដែលទទេក្រោមសម្ពាធខ្យល់ត្រជាក់។ ដៃគេម្ខាងបានបបោសស្បែកទទេលើត្រគាករបស់ខ្ញុំ ធ្វើឱ្យសំណើមដែលនៅសល់ដោយមាត់របស់គេ នៅស្អិតៗគ្រប់ចំណុចពិសេសនៃ រាងកាយរបស់ខ្ញុំ។

គេសង្កត់មកលើខ្ញុំទល់នឹងបង្កាន់ដៃដែក ប៉ុន្តែខ្ញុំលែងមានអារម្មណ៍កក់ក្ដៅទៀតហើយ....វាឈឺពិតមែន...

«ខ្ញុំឈឺណាស់ Will»

គេបានឈប់ស្ងៀមលែងរុលមក។ ភ្នែកគេបានសម្លឹងខ្ញុំជាមួយទឹកមុខស្លូតបូត មាត់គេបន្ទាប់មកដល់ថ្ពាសខ្ញុំហើយថើបនៅសំងំកន្លែងនោះ។

«តទៀតបានទេ?»

ធម្មតាខ្ញុំដឹងថាតបនឹងរាងកាយនេះមិនរួចទៅហើយ។

«បើអត់ទេ ពេលណាក៏បាន!» គេថាហើយបានថើបចិញ្ចើមរបស់ខ្ញុំ។ កម្ដៅស្នេហាបានហូរកាត់ខ្ញុំបណ្ដេញភាពត្រជាក់ចេញអស់។ ពីរនាក់យើងបែកញើសជោគ។ តើរោមចិញ្ចើមរបស់ខ្ញុំក្លាយជាតំបន់គួរឱ្យចង់ថើបផ្ដិតតាំងពីពេលណា?

«ហួសហេតុហើយ!» ខ្ញុំខ្សឹប។

«នាងហៅខ្ញុំមកជេស៊ី! នាងឱ្យសញ្ញាតម្រេក ខ្ញុំធុំក្លិនស្នេហាដែលនាងស្រេកឃ្លាន!»

ខ្ញុំនៅស្ងៀមភ័យ។ គេនេះជា....ចចកដែលដឹងក្លិនរាប់យោជន៍?

«ខ្ញុំហៅលោកមកសម្រាប់យករបស់នោះឱ្យមេខ្ញុំ!»

«ប៉ុណ្ណឹងទេ?!»

«ចង់ឃើញខ្ញុំក្នុងរបៀបនេះ?»

«នាងក្នុងរបៀបណាក៏ខ្ញុំនឹក!»

ខ្ញុំស្លន់នឹងភាពស្មោះត្រង់ក្នុងភ្នែករបស់ Will ។

«បាននិយាយម្ដងទៀត មិនប្រាកដថានោះជាអ្វីទេ! ការថើបមួយ! ខ្នមមួយ ដង្ហើមដកជាមួយគ្នានៅលើសំយ៉ាបយ៉កណ្ដាលយប់ បងចង់បានវាមកជារឿងយូរអង្វែង!»

ខ្ញុំនៅស្ងៀមសម្លឹងគេ ភ្លេចថាខ្លួនឯងអាក្រាត។ នៅពេលនេះខ្ញុំអាចបំភ្លេចពិភពលោកនេះចោលផងក៏ថាបាន។ ដៃគេនៅលើត្រគាកខ្ញុំដែលទាញខ្ញុំមិនឱ្យចេញ ពេលនេះបានដោះលែងខ្ញុំ ហើយគេថយទាំងញញឹមទៅរកទ្វារ។ ខ្ញុំនៅតែងឿងឆ្ងល់តើតាំងពីពេលណាស្លាកមាស បានស្ថិតនៅក្នុងបាតដៃរបស់ខ្ញុំ....?

យ៉ាងរហ័សនិងអំណរខ្ញុំបត់ម្រាមដៃរបស់ខ្ញុំជុំវិញវា ក្ដាប់វាខ្លាចគេមកយកវិញ។